ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន
MINISTRY OF INFORMATION

ក្រសួងព័ត៌មាន

លេខ.....✓.....ព.ម

# សេចក្តីណែនាំ
# ស្តីពី
# ការផ្សព្វផ្សាយនិងចែករំលែកព័ត៌មានលើបណ្តាញសង្គម ដោយទំនួលខុសត្រូវនិងទប់ស្កាត់ព័ត៌មានក្លែងក្លាយ

ក្នុងសេចក្តីប្រកាសរួមនៃកិច្ចប្រជុំពិសេសលើកទី៣របស់គណៈកម្មាធិការព្រំដែនទូទៅ (GBC) រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ដែលត្រូវបានចុះហត្ថលេខាដោយកម្ពុជា-ថៃ នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥ ក្នុងវិធានការកាត់បន្ថយភាពតានតឹង ត្រង់ចំណុចទី៨ «*ភាគីទាំងពីរបានឯកភាពគ្នាជៀសវាងការចែកចាយព័ត៌មានមិនពិត ឬ ព័ត៌មានក្លែងក្លាយ ដើម្បីកាត់បន្ថយភាពតានតឹង កាត់បន្ថយសាធារណមតិអវិជ្ជមាន និងលើកកម្ពស់បរិយាកាសអំណោយផលសម្រាប់កិច្ចសន្ទនាដោយសន្តិវិធី*»។

ដើម្បីចូលរួមក្នុងការអនុវត្តវិធានការខាងលើនេះឱ្យមានប្រសិទ្ធភាព ក៏ដូចជាគាំទ្រដល់លទ្ធផលនៃសេចក្តីប្រកាសរួមឱ្យបានពេញលេញ ពិសេសក្នុងដំណាក់កាលកម្ពុជានិងថៃ កំពុងកសាងទំនុកចិត្តគ្នា ដើម្បីមានបទឈប់បាញ់អចិន្ត្រៃយ៍ មានសន្តិភាពឡើងវិញ ក្រសួងព័ត៌មានសូមធ្វើការណែនាំដល់សាធារណជន និងអ្នកប្រកបអាជីពក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ ដូចតទៅ៖

១-សូមបន្តតាមដាន និងទទួលព័ត៌មានពីប្រភពព័ត៌មានផ្លូវការ, ចែកចាយព័ត៌មាន ដែលមានប្រភពច្បាស់លាស់ ព្រមទាំងជឿជាក់លើប្រព័ន្ធផ្សព្វផ្សាយដែលគោរពក្រមសីលធម៌វិជ្ជាជីវៈត្រឹមត្រូវក្នុងការផលិតនិងផ្សាយព័ត៌មាន។ ប្រភពព័ត៌មានផ្លូវការរួមមាន៖ ក) ថ្នាក់ដឹកនាំកំពូលរបស់ជាតិ, ខ) ក្រសួងការពារជាតិ, គ) ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ, ឃ) ក្រសួងព័ត៌មាន, ង) ក្រសួងមហាផ្ទៃ, ច) រដ្ឋលេខាធិការដ្ឋានទទួលបន្ទុកកិច្ចការព្រំដែន, និង ឆ) អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជា។

២-សូមកុំបង្កើត ឬផ្សាយព័ត៌មានក្លែងក្លាយ និងសូមកុំចែករំលែកព័ត៌មានគ្មានប្រភពច្បាស់លាស់ ដែលអាចបង្កអន្តរាយដល់សន្តិភាព និងប៉ះពាល់ដល់ដំណើរការអនុវត្តសេចក្តីប្រកាសរួមនេះ។

៣-សូមប្រើប្រាស់បណ្តាញសង្គមដោយក្រមសីលធម៌ និងទំនួលខុសត្រូវ ជៀសវាងការបង្ហោះ ឬផ្សព្វផ្សាយព័ត៌មានដែលមានចរិតញុះញង់ ការជេរប្រមាថ ឌឺដង ប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូរ ឬបង្កការយល់ច្រឡំក្នុងសាធារណមតិ។

៤-សូមចូលរួមផ្សព្វផ្សាយ និងចែករំលែកព័ត៌មានពិត ដោយផ្ទៀងផ្ទាត់ប្រភពឱ្យបានត្រឹមត្រូវ។ ត្រូវចៀសវាងការបង្កើតមាតិកាដែលគ្មានមូលដ្ឋានពិតប្រាកដ ឬការអះអាងគ្មានភស្តុតាង ឬការប្រើពាក្យពេចន៍ ដែលអាចបង្កអន្តរាយដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ឬនាំឱ្យមានផលវិបាកនានា។

អគារលេខ ៦២ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
Building 62, Monivong BLVD, Sangkat Srah Chork, Khan Daun Penh, Phnom Penh E-mail:information@info.gov.kh

៥-សូមអ្នកបង្កើតមាតិកា និងអ្នកប្រើប្រាស់បណ្ដាញសង្គម បញ្ឈប់នូវការកាត់តរូបភាពវីដេអូ ឬបង្កើតរូបភាពបញ្ញាសិប្បនិម្មិត(AI) ដែលមានលក្ខណៈជេរប្រមាថ ការប្រើប្រាស់ភាសាមិនសមរម្យ ឬការជៀមដាម ឬសកម្មភាពផ្សេងទៀតដែលបង្អាប់អភិភាព ឬការបញ្ឆេះកំហឹងនាំឱ្យមានការរើសអើងប្រកាន់ពូជសាសន៍ជាដើម។

ជាមួយគ្នានេះ ក្រសួងព័ត៌មានសូមក្រើនរំឭកដល់អ្នកអនុវត្តសកម្មភាពក្នុងវិស័យព័ត៌មាន និងសោតទស្សន៍ រួមទាំងសាធារណជនទាំងអស់ ចូលរួមក្នុងការទប់ស្កាត់ព័ត៌មានក្លែងក្លាយ ដោយមិនត្រូវបង្កើត ផ្សព្វផ្សាយ ឬចែករំលែកព័ត៌មានក្លែងក្លាយ ការប្រឌិតឬកាឡៃព័ត៌មានខុសពីការពិត។ ក្រសួងព័ត៌មានសូមជំរុញ និងលើកទឹកចិត្តដល់អ្នកអនុវត្តសកម្មភាពក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ រួមទាំងសាធារណជនទាំងអស់ឱ្យផលិត ផ្សព្វផ្សាយ ចែកចាយតែព័ត៌មានពិត ដែលមានប្រភពច្បាស់លាស់ និងការផ្ទៀងផ្ទាត់ត្រឹមត្រូវ។

ក្រសួងព័ត៌មានជឿជាក់ថា ការចូលរួមយ៉ាងសកម្មរបស់ប្រជាពលរដ្ឋក្នុងការផ្សព្វផ្សាយព័ត៌មានពិត និងទប់ស្កាត់ព័ត៌មានក្លែងក្លាយ នឹងរួមចំណែកជំរុញឱ្យមានការអនុវត្តពេញលេញនូវសេចក្ដីប្រកាសនេះ ដើម្បីធ្វើឱ្យមានបទឈប់បាញ់អចិន្ត្រៃយ៍ និងក្លាយជាមូលដ្ឋានរឹងមាំសម្រាប់សន្តិភាព ស្ថិរភាព និងអភិវឌ្ឍន៍សង្គម៕

ថ្ងៃសៅរ៍ ៨កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥

ក្រសួងព័ត៌មាន